# សៀវភៅណែនាំ អំពី ៖
# យុទ្ធសាស្ត្រផ្សព្វផ្សាយពី
# កសិករទៅកសិករសម្រាប់
# វារីវប្បកម្មទឹកសាបទ្រង់ទ្រាយតូច



2015

# សៀវភៅណែនាំ
# អំពី
# យុទ្ធសាស្ត្រផ្សព្វផ្សាយពីកសិករទៅកសិករ
# សម្រាប់
# វារីវប្បកម្មទឹកសាបទ្រង់ទ្រាយតូច

**(Guidebook on Farmer-to-Farmer Extension Approach for Small-scale Freshwater Aquaculture)**


**Japan International Cooperation Agency**
Nibancho Center Building 5-25
Niban-cho, Chiyoda-ku
Tokyo 102-8012
Japan
www.jica.go.jp

**Network of Aquaculture Centres In Asia-Pacific**
Suraswadi Building
Kasetsart University Campus
Ladyao, Jatujak, Bangkok 10900
Thailand
www.enaca.org

2015

**@ 2015, Japan International Cooperation Agency and Network of Aquaculture Centres in Asia-Pacific.**

*No part of this book may be reproduced in any form by print, photoprint, microfilm or any other means without permission from the publishers.*

**Citation:**

JICA and NACA, 2015. ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន និងបណ្តាញមជ្ឈមណ្ឌលវារីវប្បកម្មក្នុងតំបន់អាស៊ី ប៉ាស៊ីហ្វិកឆ្នាំ២០១៥ (Guidebook on Farmer-to-Farmer Extension Approach for Small-scale Freshwater Aquaculture). Japan International Cooperation Agency, Tokyo Japan, Network of Aquaculture Centres in Asia-Pacific, Bangkok, Thailand. 24 pp.

# សាររបស់អង្គការយ៉ៃកា (JICA)

នៅក្នុងកិច្ចប្រជុំកំពូលស្តីពីការអភិវឌ្ឍប្រកបដោយនិរន្តរភាពរបស់អង្គការសហប្រជាជាតិ ដែលបាន ធ្វើឡើងនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ បណ្តាមេដឹកនាំរដ្ឋនានានៅលើពិភពលោក បានអនុម័តនូវកិច្ចការ ដែលត្រូវអភិវឌ្ឍប្រកបដោយនិរន្តភាពដល់ឆ្នាំ២០៣០ ដែលរួមបញ្ចូលនូវគោលដៅនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពចំនួន១៧ ដើម្បីបញ្ចប់ភាពក្រីក្រ ការប្រយុទ្ធប្រឆាំងនឹងភាពអយុត្តិធម៌ ភាពមិនស្មើភាពគ្នា ព្រមទាំងការតស៊ូជំនះនឹងការប្រែប្រួលអាកាសធាតុដល់ឆ្នាំ២០៣០ ហើយមានការរំពឹងទុកថាគ្រប់បណ្តាប្រទេសជាសមាជិកអង្គការសហប្រជាជាតិនឹងពាំនាំនូវការអនុម័តនេះ ដើម្បីយកទៅរៀបចំជាគោលនយោបាយជាតិរបស់ខ្លួន ជាពិសេសគោលនយោបាយ ODA នៅក្នុងរយៈពេល ១៥ឆ្នាំបន្ទាប់ទៅទៀត។

អ្វីដែលគួរកត់សំគាល់ចំពោះកិច្ចការនេះគឺថាវិស័យជលផលត្រូវបានគេដាក់បញ្ចូលជាគោលដៅ ១ ក្នុងចំណោមគោលដៅទាំង ១៧ នៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព រួមជាមួយនឹងបញ្ហាជាសាកលសំខាន់ៗដទៃទៀត ដូចជាភាពក្រីក្រ  សុខភាព ការអប់រំ  និងបម្រែបម្រួលអាកាសធាតុ ។ គោលដៅនេះគឺជាគោលដៅទី១៤ ដែលមានឈ្មោះថា“ អភិរក្ស និងប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវតំបន់មហាសមុទ្រ និងធនធានសមុទ្រដទៃទៀត ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព ” ។

ឆ្លើយតបនឹងសារៈសំខាន់នៃនិរន្តរភាពវិស័យជលផល នៅក្នុងគោលនយោបាយដ៏សំខាន់នេះ អង្គការយ៉ៃកា JICA បច្ចុប្បន្នបានយកចិត្តទុកដាក់ខ្លាំងទៅលើផ្នែកវារីវប្បកម្ម។ អង្គការយ៉ៃកា JICA យល់ថា ត្រីកំពុងរួមវិភាគទានយ៉ាងធំធេងដល់សន្តិសុខស្បៀង ចំណីអាហារ និងការនាំចេញ ហើយតម្រូវការសាច់ត្រីកំពុងបន្តការកើនឡើង គឺមានតែការអភិវឌ្ឍវារីវប្បកម្មទេដែលអាចដោះស្រាយបញ្ហានេះបាន។ ក្នុងពេលជាមួយគ្នានេះ ដើម្បីបង្កើនផលិតកម្មវារីវប្បកម្មប្រកបដោយនិរន្តរភាព គឺយើងគួរតែកាត់បន្ថយនូវការប្រើប្រាស់ធនធានត្រីធម្មជាតិ ដូចជាការចាប់ពូជត្រីមកចិញ្ចឹម និងធ្វើជាចំណី ព្រមទាំងយកចិត្តទុកដាក់ធ្វើការត្រួតពិនិត្យជំងឺត្រី ការប្រើប្រាស់ថ្នាំ និងកាត់បន្ថយនូវការប៉ះពាល់បរិស្ថានពាក់ព័ន្ធនឹងសកម្មភាពវារីវប្បកម្ម។

វារីវប្បកម្មទឹកសាបទ្រង់ទ្រាយតូចបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចបាននូវគោលបំណងខាងលើ ពីព្រោះវាអាចផ្គត់ផ្គង់នូវប្រូតេអ៊ីនជាតិសាច់ និងអាហារូបត្ថម្ភដល់សហគមន៍ជនបទប្រចាំថ្ងៃក្នុងកម្រិតចំណាយទាប។ ទោះបីជាយ៉ាងនេះក្តី ក្នុងពេលចាប់ផ្តើមដំបូងការជម្រុញសកម្មភាពវារីវប្បកម្មទឹកសាបទ្រង់ទ្រាយតូចតែងតែជួបប្រទះនូវបញ្ហាជាច្រើន។ បញ្ហាទាំងនោះដូចជា កសិករខ្វះចំណេះដឹងជាមូលដ្ឋាន ខ្វះចំណេះដឹងបច្ចេកទេសលើការចិញ្ចឹមត្រី ខ្វះពូជត្រី ពិបាករកត្រីពូជមកដាក់ចិញ្ចឹម សេវាកម្មផ្សព្វផ្សាយបច្ចេកទេសដល់កសិករមិនបានគ្រប់គ្រាន់តាមតម្រូវការ ជាដើម។ល។ នៅតាមបណ្តាប្រទេសមួយចំនួន ដូចជាកម្ពុជា ឡាវ ភូមា ម៉ាដាហ្គាស្កា និងប៉េនីន អង្គការយ៉ៃកា JICA បាននឹងកំពុងអនុវត្តគម្រោងសហប្រតិបត្តិការបច្ចេកទេស្រដៀងគ្នា ពាក់ព័ន្ធនឹងការផ្សព្វផ្សាយវារីវប្បកម្មទ្រង់ទ្រាយតូច ដែលបញ្ហាដូចខាងលើនេះ ត្រូវបានដោះស្រាយបានយ៉ាងទូលំទូលាយ តាមរយៈការអភិវឌ្ឍកសិករផលិតកូនត្រីពូជ និងយុទ្ធសាស្ត្រផ្សព្វផ្សាយពីកសិករទៅកសិករ។ នេះជាហេតុផលមួយយ៉ាងសំខាន់ ដែលចាំបាច់ត្រូវរៀបចំចងក្រងសៀវភៅណែនាំនេះ ដើម្បីចែករំលែកមេរៀនជាបទពិសោធន៍ និងចំណេះដឹង ជាមួយបណ្តាប្រទេសនិងអង្គការដៃគូរអភិវឌ្ឍន៍ឱ្យបានច្រើនទៅតាមលទ្ធភាពដែលអាចធ្វើបាន។

សៀវភៅណែនាំនេះ គឺជាស្នាដៃទី ២ នៃកិច្ចសហប្រតិបត្តិការរវាងអង្គការយ៉ៃកា JICA និងអង្គការ NACA (បណ្តាញមជ្ឈមណ្ឌលវារីវប្បកម្មក្នុងតំបន់អាស៊ី ប៉ាស៊ីហ្វិក) បន្ទាប់ពី “សន្និសិទអន្តរជាតិអំពីការផ្សព្វផ្សាយវារីវប្បកម្មទ្រង់ទ្រាយតូច ” ត្រូវបានរៀបចំឡើងប្រកបដោយជោគជ័យ នៅទីក្រុងបាងកក ប្រទេសថៃ កាលពីខែតុលា ឆ្នាំ២០១៣ ។ ជាការពិតណាស់ ប្រសិនបើពុំមានការគាំទ្រពីអង្គការ NACA នោះទេ ឯកសារនេះនឹងមិនអាចរៀបចំឡើងបានឡើយ ដូចនេះ ជំនួសមុខឱ្យអង្គការយ៉ៃកា JICA ខ្ញុំសូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះការជួយគាំទ្រដ៏មានតម្លៃ និងកិច្ចសហប្រតិបត្តិការពីអង្គការ NACA ក្នុងការរៀបចំឯកសារនេះឡើង។

***Makoto Kitanaka***
អគ្គនាយក
នៃនាយកដ្ឋានអភិវឌ្ឍជនបទ

# សាររបស់អង្គការណាកា (NACA)

វារីវប្បកម្មទ្រង់ទ្រាយតូចគឺជាផ្នែកមួយយ៉ាងសំខាន់នៃគម្រោងមួយចំនួនដែលត្រូវបានអនុវត្ត ដោយអង្គការណាកា NACA (បណ្តាញមជ្ឈមណ្ឌលវារីវប្បកម្មក្នុងតំបន់អាស៊ី ប៉ាស៊ីហ្វិក) នៅក្នុង បណ្តាឆ្នាំកន្លងមក។ ដូចមានចែងនៅក្នុងអាណត្តិរបស់ខ្លួនថា អង្គការ NACA គឺជាអង្គការ អន្តររដ្ឋាភិបាលដែលជម្រុញកិច្ចអភិវឌ្ឍនៅតាមជនបទតាមរយៈការអភិវឌ្ឍវារីវប្បកម្ម និង គ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព។ អង្គការណាកា NACA ជួយគាំទ្រដល់ការកែ លម្អមុខរបរចិញ្ចឹមជីវិតប្រជាជននៅតាមជនបទឱ្យកាន់តែប្រសើរ ឡើង កាត់បន្ថយភាពក្រីក្រ និងបង្កើនសន្តិសុខស្បៀង សម្រាប់គ្រួសារកសិករនិងសហគមន៍ចិញ្ចឹមត្រី ដែលជាអ្នកទទួល ផលយ៉ាងសំខាន់បំផុតពីគម្រោង។ អង្គការណាកា NACA អនុវត្តគម្រោងផ្តល់ជំនួយសម្រាប់កិច្ច អភិវឌ្ឍក្នុងភាពជាដៃគូជាមួយមជ្ឈមណ្ឌលស្រាវជ្រាវ រដ្ឋាភិបាល ភ្នាក់ងារអភិវឌ្ឍនានា សមាគមកសិករនិងជាមួយអង្គការដទៃទៀត។ អង្គការណាកាក៏បានជួយគាំទ្រដល់ការផ្លាស់ប្តូ របច្ចេកទេស និងការកសាងសមត្ថភាព ជួយពង្រឹងស្ថាប័ន និងការអភិវឌ្ឍគោលនយោបាយ ដើម្បីអភិវឌ្ឍវារីវប្បកម្ម និងគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាពផងដែរ។

ការរៀបចំសៀវភៅណែនាំស្តីពីយុទ្ធសាស្ត្រផ្សព្វផ្សាយពីកសិករទៅកសិករ សម្រាប់ការអភិវឌ្ឍវារី វប្បកម្ម ទ្រង់ទ្រាយតូច គឺស្របតាមពេលវេលាដ៏ល្អបំផុត និងមានភាពចាំបាច់សម្រាប់កម្មវិធី ការងារទាំងមូលរបស់អង្គការណាកា NACA ជាពិសេសចំពោះកិច្ចអភិវឌ្ឍ និងជម្រុញការ ផ្សព្វផ្សាយវារីវប្បកម្មទ្រង់ទ្រាយតូច។ ផ្អែកតាមលទ្ធផលដែលទទួលបានជាពីការអនុវត្តគម្រោង របស់អង្គការយ៉ៃកា JICA នៅក្នុងប្រទេសកម្ពុជា ឡាវ និងនៅបណ្តាប្រទេសដ៏ទៃទៀត ក្នុងតំបន់ អាស៊ី និងតំបន់អាហ្វ្រិក បានបង្ហាញពីប្រសិទ្ធភាពនៃយុទ្ធសាស្ត្រផ្សព្វផ្សាយពីកសិករទៅកសិករ គឺជាយុទ្ធសាស្ត្រផ្សព្វផ្សាយដ៏សាមញ្ញ ប៉ុន្តែមានលក្ខណបច្ចេកវិទ្យាដែលអាចអនុវត្តបានចំពោះ ការចិញ្ចឹមត្រី និងផលិតកូនត្រី ជាពិសេសនៅក្នុងសហគមន៍ជនបទដែលការផ្សព្វផ្សាយព័ត៌មាន និងការផ្ទេរបច្ចេកវិទ្យានៅមានកម្រិតតិចតួចនៅឡើយ។

កិច្ចសហការរួមគ្នារបស់អង្គការណាកា NACA ជាមួយអង្គការយ៉ៃកា JICA អំពីការផ្សព្វផ្សាយវារីវប្បកម្មទ្រង់ទ្រាយតូចដែលបានអនុវត្តកន្លងមកនេះ គឺទទួលបានលទ្ធផលជោគជ័យយ៉ាងធំធេង។ តាងនាមអង្គការណាកា NACA ខ្ញុំរំពឹងថានឹងមានកិច្ចសហការជាបន្តទៀតក្នុងការអនុវត្តតាមសៀវភៅណែនាំនេះ ដើម្បីលើកកម្ពស់កិច្ចអភិវឌ្ឍវារីវប្បកម្មទ្រង់ទ្រាយតូចនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា វគ្គ  បណ្តុះបណ្តាលមួយនឹងអាចត្រូវរៀបចំឡើងនៅពេលអនាគត ដោយផ្អែកលើសៀវភៅណែនាំដ៏មានសារៈសំខាន់នេះ។

***Cherdsak Virapat, PhD***
អគ្គនាយក

# អារម្ភកថា

សៀវភៅណែនាំនេះត្រូវបានរៀបចំឡើង គឺជាលទ្ធផលមួយដែលកើតចេញពីសន្និសិទអន្តរជាតិស្តីពី ការផ្សព្វផ្សាយវារីវប្បកម្មទឹកសាបទ្រង់ទ្រាយតូច ដែលបានប្រព្រឹត្តទៅនៅទីក្រុងបាំងកក ប្រទេសថៃ កាលពីខែតុលា ឆ្នាំ២០១៣[1]។

បទពិសោធន៍ប្រកបដោយភាពជោគជ័យជាច្រើនរបស់កសិករចិញ្ចឹមត្រីទ្រង់ទ្រាយតូច ក្នុងបណ្តាប្រទេសអាស៊ាន និងអាហ្វ្រិកបាននាំមកនូវការយល់ដឹងយ៉ាងច្បាស់ពីប្រសិទ្ធភាព និងយន្តការដែលកសិករអាចដំណើរការបានដោយខ្លួនឯងនូវយុទ្ធសាស្ត្រផ្សព្វផ្សាយវារីវប្បកម្មពីកសិករទៅកសិករ។ នេះជាគ្រោងការណ៍មួយដែលត្រូវបានរៀបចំឡើងដោយអង្គការយ៉ៃកា JICA ក្នុងការអនុវត្តគម្រោងសហប្រតិបត្តិការបច្ចេកទេសនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍមួយចំនួនក្នុងតំបន់ ដើម្បីការអភិវឌ្ឍវារីវប្បកម្មនៅតាមជនបទ។

ព័ត៌មានដែលបានប្រើនៅក្នុងសៀវភៅណែនាំនេះ គឺភាគច្រើនទទួលបានពីលទ្ធផលនៃការអនុវត្តគម្រោងបង្កើនលទ្ធភាព និងផ្សព្វផ្សាយវារីវប្បកម្មទឹកសាបដំណាក់កាលទី១ និងទី២ នៅក្នុងប្រទេសកម្ពុជា។ លើសពីនេះក្នុងសៀវភៅណែនាំនេះក៏បានបញ្ចូលផងដែរនូវលទ្ធផលដែលបានមកពីកិច្ចពិភាក្សាក្នុងពេលសន្និសិទអន្តរជាតិ ព្រមទាំងព័ត៌មានដែលបានមកពីការធ្វើការសំភាសន៍ជាមួយកសិករចិញ្ចឹមត្រី និងកសិករផលិតកូនត្រីនៅក្នុងខេត្តមួយចំនួននៃប្រទេសកម្ពុជា។

សៀវនេះនឹងផ្តល់នូវការណែនាំអំពីរបៀបនៃការអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយវារីវប្បកម្មពីកសិករទៅកសិករ ដែលបានមកពីបទពិសោធន៍នៃការអនុវត្តគម្រោងបង្កើនលទ្ធភាពនិងផ្សព្វផ្សាយវារីវប្បកម្មទឹកសាប ដំណាក់កាលទី១ និងទី២ នៅតំបន់ជនបទ នៅក្នុងប្រទេសកម្ពុជា ប្រកបដោយជោគជ័យ។ សៀវភៅណែនាំនេះអាចធ្វើការកែប្រែបាន អាស្រ័យទៅនឹងលក្ខខណ្ឌនិងស្ថានភាពជាក់ស្តែងក្នុងតំបន់ ក៏ដូចជាស្របតាមកម្មវិធីផ្សព្វផ្សាយវារីវប្បកម្មដែលនឹងត្រូវអនុវត្ត។ មានការរំពឹងទុកផងដែរថា សៀវភៅណែនាំនេះអាចត្រូវបានកែសម្រួលឱ្យសម

[1] Proceedings of the symposium is available for free download at NACA (www.enaca.org), JICA Thailand (www.jica.go.jp/thailand/english/office/) and JICA (www.jica.go.jp) websites.

ស្របទៅនឹងការអនុវត្តគម្រោងវារីវប្បកម្មទ្រង់ទ្រាយតូចនៅបណ្តាប្រទេសក្នុងតំបន់ (ដូចជាការអនុវត្តគម្រោងវារីវប្បកម្មក្នុងតំបន់ទឹកភ្លាវ និងតំបន់ឆ្នេរ ) ជាពិសេសក្នុងតំបន់ជនបទក្រីក្រ។

# សេចក្តីថ្លែងអំណរគុណ

សៀវភៅណែនាំនេះអាចបោះពុម្ពឡើងបានដោយមានការជួយឧបត្ថម្ភគាំទ្រថវិកាពីអង្គការយ៉ៃកា JICA ។ សូមថ្លែងអំណរគុណចំពោះលោកបណ្ឌិត អេឌូអាដូ លេណូ Dr. Eduardo Leaño ជាអ្នកនិពន្ធដ៏សំខាន់ដែលបានខិតខំរៀបចំសៀវភៅណែនាំនេះឡើង ហើយក៏សូមអរគុណចំពោះមន្ត្រីរដ្ឋបាលជលផល និងមន្ត្រីខណ្ឌរដ្ឋបាលជលផលដែលបានជួយសម្របសម្រួលក្នុងកំឡុងពេលចុះជួបសំភាសន៍ជាមួយកសិករចិញ្ចឹមត្រី និងកសិករផលិតកូនត្រី។ ជាពិសេសសូមថ្លែងអំណរគុណចំពោះលោក **ខិន ដា** ដែលបានជួយផ្តល់របាយការណ៍ និងរូបថតសំខាន់ៗជាច្រើនដែលប្រើក្នុងសៀវភៅណែនាំនេះ។ ជាចុងក្រោយ សូមថ្លែងអំណរគុណដល់កសិករចិញ្ចឹមត្រី និងកសិករផលិតកូនត្រីនៅខេត្តតាកែវ កំពត ពោធិសាត់ និងខេត្តបាត់ដំបងដែលបានចូលរួមក្នុងការផ្តល់នូវបទសំភាសន៍។ គ្រប់ការចូលរួមចំណែកពីអស់លោក លោកស្រីគឺជាវិភាគទានមួយដ៏ថ្លៃថ្លាក្នុងការចងក្រងសៀវភៅណែនាំនេះឱ្យបានសម្រេចចប់សព្វគ្រប់។

# មាតិកា

សាររបស់អង្គការយ៉ៃកា )JICA( ........ iii
សាររបស់អង្គការណាកា )NACA( ........ v
អារម្ភកថា ........ vii
សេចក្តីថ្លែងអំណរគុណ ........ ix
១. សេចក្តីផ្តើម ........ 1
២. យុទ្ធសាស្រ្តផ្សព្វផ្សាយពីកសិករទៅកសិករ ........ 4
៣. តួនាទីរបស់រដ្ឋាភិបាល និងភ្នាក់ងារអភិវឌ្ឍដទៃទៀត ........ 7
៤. ភារកិច្ចរបស់មន្រ្តីផ្សព្វផ្សាយរបស់រដ្ឋាភិបាល ........ 9
៤. ការជ្រើសរើសកសិករផលិតកូនត្រី និង ផ្តល់វគ្គបណ្តុះបណ្តាល ........ 10
៥. បណ្តាញកសិករផលិតកូនត្រី ........ 15
៦. ការផ្សព្វផ្សាយពីកសិករទៅកសិករ ........ 17
៧. ការត្រួតពិនិត្យ និងវាយតម្លៃ ........ 21
៨. ឯកសារយោង ........ 24

# ១. សេចក្តីផ្តើម

វារីវប្បកម្មទឹកសាបទ្រង់ទ្រាយតូចនៅក្នុងតំបន់គឺមានតាំងយូរយារណាស់មកហើយ ហើយបានផ្តល់នូវគុណប្រយោជន៍ជាច្រើនដល់កសិករ ដូចជា ការបង្កើតនូវប្រាក់ចំណូល និងការបង្កើននូវអាហារូបត្ថម្ភ ហើយការអនុវត្តសកម្មភាពវារីវប្បកម្មប្រកបដោយនិរន្តរភាព គឺត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធកសិដ្ឋានចិញ្ចឹមចម្រុះ។ នៅបណ្តាប្រទេសក្នុងតំបន់អាស៊ី សកម្មភាពវារីវប្បកម្មទ្រង់ទ្រាយតូចអាចទទួលបាននូវប្រសិទ្ធភាពតាមរយៈការអនុវត្តរួមជាមួយនឹងសេដ្ឋកិច្ចដំណាំស្រូវ ដោយមានការជួយគាំទ្របច្ចេកវិទ្យា និងផ្តល់ពូជសមស្រប។ ទោះជាយ៉ាងនេះក្តី ការអភិវឌ្ឍដ៏ចាំបាច់ និងការកែលម្អបច្ចេកវិទ្យាឱ្យបានប្រសើរឡើងមិនទាន់បានផ្តល់ឱ្យ ឬមិនទាន់ធ្វើការផ្សព្វផ្សាយទៅដល់គ្រួសារកសិករដែលរស់នៅតាមជនបទនៅឡើយ។ បញ្ហានេះគឺបណ្តាលឱ្យផលិតកម្មវារីវប្បកម្មមិនទាន់ប្រើប្រាស់ឱ្យអស់សក្តានុពលនៅឡើយនៅក្នុងសហគមន៍ជនបទ ជាពិសេសនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ។ កង្វះការផ្សព្វផ្សាយដល់កសិករដែលរស់នៅតាមជនបទនូវបច្ចេកវិទ្យាផលិតកម្មកូនត្រីពូជនិងការចិញ្ចឹមត្រី គឺបានរារាំងដល់ការអភិវឌ្ឍ និងការទទួលយកនូវ បច្ចេកវិទ្យាវារីវប្បកម្មរបស់កសិករនៅពេលអនាគត។

គំនិតផ្តួចផ្តើមរបស់អង្គការយ៉ៃកា JICA អំពីយុទ្ធសាស្ត្រផ្សព្វផ្សាយបច្ចេកវិទ្យាវារីវប្បកម្មពីកសិករទៅកសិករ បានបង្ហាញច្បាស់ថាវាជាវិធីសាស្ត្រមួយដ៏មានប្រសិទ្ធភាពក្នុងការផ្ទេរបច្ចេកវិទ្យាដល់គ្រួសារកសិករក្រីក្រនៅតាមជនបទ។ គុណប្រយោជន៍នៃយុទ្ធសាស្ត្រនេះ គឺការផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេស ដែលអាចធ្វើឡើងដោយកសិករផលិតកូនត្រី ទៅដល់កសិករទ្រង់ទ្រាយតូចដទៃទៀតនៅតាមជនបទ (ទាំងបុរសនិងស្ត្រី) តាមរយៈការអនុវត្តជាក់ស្តែងនូវបច្ចេកវិទ្យាដែលបានអភិវឌ្ឍ ដែលជាការសាកល្បងពិសោធន៍របស់កសិករផលិតកូនត្រី។ លើសពីនេះ ការផ្សព្វផ្សាយបច្ចេកវិទ្យានេះ គឺជាការផ្ទេរនូវបច្ចេកវិទ្យាដ៏មានប្រសិទ្ធភាព ពីព្រោះវាធ្វើឡើងដោយកសិករក្នុងមូលដ្ឋានផ្ទាល់។ បញ្ហាសំខាន់បំផុតនោះ គឺថាការផ្ទេរបច្ចេកវិទ្យាតាមវិធីសាស្ត្រនេះ គឺផ្អែកទាំងស្រុងលើធនធានក្នុងមូលដ្ឋានដែលមានភាពងាយស្រួលអនុវត្តបានដោយកសិករខ្លួនឯង។




**រូបភាពទី ១៖** គំនូសតាងស្ដីពីដំណើរការនៃយុទ្ធសាស្ត្រផ្សព្វផ្សាយពីកសិករទៅកសិករសម្រាប់ការអភិវឌ្ឍវារីវប្បកម្មទឹកសាបទ្រង់ទ្រាយតូច (ត្រូវបានកែសម្រួលដោយរដ្ឋបាលជលផល និងអង្គការយ៉េកាឆ្នាំ ២០១៤ )

យុទ្ធសាស្ត្រផ្សព្វផ្សាយបច្ចេកវិទ្យាវារីវប្បកម្មពីកសិករទៅកសិករ គឺអាចអនុវត្តបានដោយការរៀបចំវគ្គបណ្តុះបណ្តាលរបស់កសិករផលិតកូនត្រី ដែលកសិករទាំងនោះនឹងយកចំណេះដឹងបច្ចេកវិទ្យាដែលបានរៀនយកទៅអនុវត្ត ដើម្បីបង្កើនផលិតកម្មវារីវប្បកម្មរបស់ពួកគេ។ មានការកត់សំគាល់ថា ប្រព័ន្ធផ្សព្វផ្សាយនេះមិនត្រឹមតែបានផ្តល់នូវផលប្រយោជន៍សេដ្ឋកិច្ចដល់កសិករផលិតកូនត្រីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានពង្រឹងនូវតួនាទីកសិករក្នុងសង្គម ជាអ្នកដឹកនាំ និងជាអ្នកផ្សព្វផ្សាយនៅក្នុងមូលដ្ឋានផ្ទាល់របស់ខ្លួនទៀតផង។ ក្រោយពេលដែលកសិករផលិតកូនត្រីត្រូវបានចងក្រងជាក្រុមបណ្តាញ និងទទួលបាននូវការបណ្តុះបណ្តាលបច្ចេកទេស កសិករផលិតកូនត្រីទាំងនោះអាចធ្វើការផ្សព្វផ្សាយ និងផ្ទេរបច្ចេកទេសវារីវប្បកម្មទៅដល់កសិករផ្សេងទៀតដែលមានបំណងចង់ធ្វើការចិញ្ចឹមត្រី។ ដំណើរការផ្សព្វផ្សាយនេះនឹងត្រូវធ្វើជាបន្តពីកសិករមួយទៅកសិករដទៃទៀត ដូចនេះកសិករនៅតាមជនបទជាច្រើនគ្រួសារនឹងទទួលបាននូវផលប្រយោជន៍ ហើយយ៉ាងហោចណាស់ក៏អាចជួយដល់កសិករក្នុងការបង្កើននូវផលិតផលត្រីចិញ្ចឹមនៅក្នុងកសិដ្ឋានរបស់ខ្លួន។ ក្រៅពីនេះ ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រុមកសិករផលិតកូនត្រីពូជតាមរយៈការចងក្រងជាក្រុមបណ្តាញគឺជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពដើម្បីធានាបាននូវការអភិវឌ្ឍវារីវប្បកម្មប្រកបដោយនិរន្តភាព។

ផ្អែកលើបទពិសោធន៍ដែលអនុវត្តដោយកសិករផលិតកូនត្រីពូជនៅបណ្តាប្រទេសដែលអង្គការយ៉ៃកា JICA បានជួយឧបត្ថម្ភកន្លងមកនេះ បានបង្ហាញពីភាពជោគជ័យរបស់កសិករផលិតកូនត្រីម្នាក់ៗដែលបានស្ម័គ្រចិត្តចូលរួមសហការជាមួយគម្រោង (NACA JICA, 2013)។ ផ្តើមចេញពីដំណាក់កាលដំបូងគឺពីពេលដែលមានអាង ឬស្រះ១ ឬ២ សម្រាប់ចិញ្ចឹមត្រី ជាធម្មតាកសិករតែងតែពង្រីកកសិដ្ឋានចិញ្ចឹមត្រីរបស់ខ្លួន ហើយធ្វើការផលិតកូនត្រីកាន់តែច្រើនចេញពីអាងបង្កាត់ភ្ញាស់ និងស្រះបំប៉នកូនត្រី ហើយថែមទាំងធ្វើការចិញ្ចឹមត្រីសាច់សម្រាប់ប្រើប្រាស់ក្នុងគ្រួសារនិងលក់ទៀតផង។ កសិករផលិតកូនត្រីទាំងនេះមានសមត្ថភាពផលិតនិងផ្គត់ផ្គង់កូនត្រីពូជទៅកសិករចិញ្ចឹមត្រីដែលបានទទួលការបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីពីកសិករផលិតកូនត្រី និងបានផ្គត់ផ្គង់កូនត្រីពូជទៅកសិករដ៏ទៃទៀត ហើយថែមទាំងបានលក់ត្រីសាច់ខ្លះទៅផ្សារក្នុងតំបន់ដើម្បីទទួលបានប្រាក់ចំណូលថែមទៀតផង។ ឆន្ទៈដ៏ល្អរបស់កសិករផលិតកូនត្រីក្នុងការ   បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីដល់កសិករដទៃទៀតក្នុងមូលដ្ឋាន និងការចែក

វលែកបទពិសោធន៍បច្ចេកទេស ក៏ដូចជាជួយដល់កសិករនៅក្នុងមូលដ្ឋានទាំងនោះ គឺបានធ្វើឱ្យមានការកើនឡើងនូវផលិតកម្មត្រីចិញ្ចឹមទាំងនៅក្នុងមូលដ្ឋាន និងនៅឃុំជិតខាង។

ក្នុងករណីខ្លះកសិករចិញ្ចឹមត្រីដែលបានទទួលនូវការបណ្តុះបណ្តាលបច្ចេកទេសពីកសិករផលិតកូនត្រី បានក្លាយជាកសិករផលិតកូនត្រីដោយខ្លួនឯងបាន ហើយមានសមត្ថភាពបណ្តុះបណ្តាលនិងជួយផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រីបន្តទៅកសិករដទៃទៀត។ ទោះបីជាមានបញ្ហាខ្លះៗបានកើតឡើងក្នុងពេលអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយនេះក៏ដោយ (ដូចជាលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសកសិករផលិតកូនត្រី ឆន្ទៈរបស់កសិករស្ម័គ្រចិត្តចូលរួមជាមួយសកម្មភាពគម្រោង) ក៏លទ្ធផលទទួលបានពីការអនុវត្តគម្រោងដែលឧបត្ថម្ភដោយអង្គការយ៉ៃកា JICA នៅក្នុងបណ្តាប្រទេសមួយចំនួនក្នុងតំបន់បានបង្ហាញពីប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយនេះ ក្នុងការធានាបាននូវការអនុវត្តបន្តនូវកិច្ចការផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្មពីកសិករមួយទៅកសិករដទៃទៀតជាប់ជាប្រចាំ។

# ២. យុទ្ធសាស្ត្រផ្សព្វផ្សាយពីកសិករទៅកសិករ

ក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ មានគម្រោងសហប្រតិបត្តិការបច្ចេកទេសរបស់អង្គការយ៉ៃកា **JICA** ជាច្រើនបានប្តូរពីគម្រោងអភិវឌ្ឍនិងស្រាវជ្រាវ ទៅជាគម្រោងផ្តល់សេវាកម្មផ្សព្វផ្សាយបច្ចេកទេសទៅដល់កសិករ ហើយជាលទ្ធផលគឺបានរៀបចំគម្រោងមួយចំនួនដែលពាក់ព័ន្ធជាមួយសកម្មភាពផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្មទ្រង់ទ្រាយតូច (**Chikami, 2013**)។ ទោះបីជាការផ្ទេរចំណេះដឹងបច្ចេកទេសវារីវប្បកម្មទទួលបានជោគជ័យយ៉ាងណាក៏ដោយ ប៉ុន្តែការយកទៅអនុវត្តតាមជាគំរូ ឬការពង្រីកយុទ្ធសាស្ត្រផ្សព្វផ្សាយទៅកន្លែងផ្សេងទៀតពុំមានភាពងាយស្រួលឡើយ ពីព្រោះថាមជ្ឈមណ្ឌលភាគច្រើនដែលទាក់ទងនឹងការងារផ្សព្វផ្សាយ មិនមានភាពទទួលខុសត្រូវចំពោះសេវាកម្មផ្សព្វផ្សាយទូទាំងប្រទេសឡើយ។ លើសពីនេះ ប្រព័ន្ធផ្សព្វផ្សាយរបស់រាជរដ្ឋាភិបាល ជាពិសេសនៅបណ្តាប្រទេសកំពុងអភិវឌ្ឍ គឺជួបប្រទះនូវការលំបាកជាច្រើនដូចជាប្រាក់បំណាច់មិនគ្រប់គ្រាន់ ខ្វះឧបករណ៍សម្ភារបំពេញការងារផ្សព្វផ្សាយ និងខ្វះអ្នកដែលទទួលបាននូវការបណ្តុះបណ្តាលបច្ចេកទេស (Chikami, 2013 )។




**រូបភាពទី ២៖** និរន្តរភាពនៃការអភិវឌ្ឍវារីវប្បកម្មទ្រង់ទ្រាយតូច ស្ថិតនៅក្រោមបរិស្ថាននៃបច្ចេកវិទ្យាផលិតកម្មវារីវប្បកម្ម (អង្គការយ៉េកា អង្គការណាកា និងរដ្ឋបាលជលផល ឆ្នាំ២០១៣ )

បញ្ហាទាំងនេះគឺធ្វើឱ្យខ្វះពូជត្រី ដែលជាឧបសគ្គរាំងស្ទះ យ៉ាងសំខាន់ដល់ដំណើរការអភិវឌ្ឍវារីវប្បកម្មទ្រង់ទ្រាយតូច។

ដើម្បីដោះស្រាយបាននូវបញ្ហាទាំងនេះ យុទ្ធសាស្ត្រផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្មពីកសិករទៅកសិករត្រូវបានស្នើ និងរៀបចំឡើង និងអនុវត្តនៅក្នុងបណ្តាប្រទេសអាស៊ានសំខាន់ៗមួយចំនួនដែលមានសកម្មភាពវារីវប្បកម្មទឹកសាបទ្រង់ទ្រាយតូច។ កិច្ចការនេះមានគោលបំណងបំពេញបន្ថែមនូវការងារផ្សព្វផ្សាយរបស់រដ្ឋាភិបាល ដើម្បីធ្វើឱ្យប្រសើរឡើង និងជាពិសេសជួយដល់កសិករក្រីក្រនៅតាមជនបទទទួលបានបច្ចេកទេសវារីវប្បកម្មកាន់តែច្រើនឡើងថែមទៀត។ លក្ខណៈពិសេសនៃយុទ្ធសាស្ត្រផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្មពីកសិករទៅកសិករនេះ គឺជាយន្តការមួយដែលកសិករអាចដំណើរការបានដោយខ្លួនឯងក្នុងការធានាបាននូវការអភិវឌ្ឍវារីវប្បកម្មប្រកបដោយនិរន្តរភាព ដោយមាន ឬមិនចាំបាច់មានការជួយជ្រោមជ្រែងពីរដ្ឋាភិបាល។ យន្តការផ្សព្វផ្សាយនេះមានបង្ហាញនៅក្នុងរូបភាពទី ១ ដូចខាងក្រោម ៖




**រូបភាពទី ៣៖** ផ្ទាំងរូបភាពមេរៀនពន្យល់អំពីបច្ចេកទេសចិញ្ចឹមត្រីរបស់កសិករ សម្រាប់បង្រៀនកសិករចិញ្ចឹមត្រីក្នុងមូលដ្ឋាន នៅពេលអនុវត្តសកម្មភាពផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្ម (រូបថតផ្តល់ដោយរដ្ឋបាលជលផល ប្រទេសកម្ពុជា)

ភាពជោគជ័យនឹងអាចទទួលបានក្នុងការអនុវត្តនូវយុទ្ធសាស្ត្រផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្មពីកសិករទៅកសិករ នៅពេលដែលកសិករដែលចាប់ផ្តើមចិញ្ចឹមត្រីដំបូងអាចអនុវត្តបាននូវបច្ចេកទេសវារីវប្បកម្មដោយគ្មាន ឬមានថវិកាដ៏តិចតួចបំផុត ឬមានជីវភាពរស់នៅលំបាក។ ដើម្បីដោះស្រាយបាននូវបញ្ហានេះ ការពង្រីកបច្ចេកទេសចិញ្ចឹមត្រីគួរតែមានភាពសាមញ្ញ ងាយស្រួលក្នុងការអនុវត្ត និងចំណាយដើមទុនតិច។ តាមបទពិសោធន៍ បច្ចេកទេសដែលបានចែករំលែកដោយកសិករចិញ្ចឹមត្រី ក្នុងបណ្តាប្រទេសមួយចំនួនដែលបានអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្មពីកសិករទៅកសិករនេះ បានបង្ហាញថាប្រភេទត្រីសមស្របបំផុតដែលអាចយកមកផ្សព្វផ្សាយសម្រាប់កសិករក្រីក្រអនុវត្តបាន គឺជាប្រភេទត្រីមិនស៊ីសាច់ជាអាហារចំបង តែស៊ីរុក្ខជាតិ កាកសំណល់បន្លែផ្សេងៗ ដូចជាប្រភេទត្រីទីឡាព្យ៉ា កាបស ត្រីកាបម្រីហ្គាល់ រ៉ូហ៊ូ និងប្រភេទត្រីកាបឥណ្ឌា ឬប្រភេទត្រីកាបចិនដទៃទៀត ។ ប្រភេទត្រីទាំងនេះ មានភាពសមស្របសម្រាប់ការដាក់ចិញ្ចឹមក្នុងស្រះដីដែលមានទំហំតូច (ជាស្រះដីមានលក្ខណៈសាមញ្ញមានទំហំតូចនៅជាប់ផ្ទះកសិករ) និងប្រើប្រាស់ដើមទុនតិចក្នុងរយៈពេលចិញ្ចឹម ដូចជាការប្រើប្រាស់ចំណីជាដើម ដោយមិនចាំបាច់ទិញចំណីគ្រាប់ឡើយ ។

ម៉្យាងទៀតការអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយនេះ បានផ្តល់នូវឱកាសស្មើៗគ្នាទាំងបុរស និងស្ត្រី ក្នុងការទទួលបាននូវព័ត៌មាននិងបទពិសោធន៍បច្ចេកទេស។

ជាទូទៅលទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយពីកសិករទៅកសិករនូវបច្ចេកទេសវារីវប្បកម្មទឹកសាបទ្រង់ទ្រាយតូចនៅក្នុងបណ្តាប្រទេសអាស៊ានសំខាន់ៗមួយចំនួន (ដូចជា ប្រទេសឡាវ និងប្រទេសកម្ពុជា) អាចមានសក្តានុពលក្នុងការអនុវត្តក្នុងប្រព័ន្ធវារីវប្បកម្មទ្រង់ទ្រាយតូចផ្សេងទៀត (ដូចជាក្នុងតំបន់ទឹកភ្លាវ និងទឹកសមុទ្រ)។ បច្ចេកវិទ្យានេះក៏អាចត្រូវបានអនុវត្តក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍដទៃទៀតនៅក្នុងពិភពលោកដែលមានសកម្មភាពវារីវប្បកម្មទ្រង់ទ្រាយតូចផងដែរ។

# ៣. តួនាទីរបស់រដ្ឋាភិបាល និងភ្នាក់ងារអភិវឌ្ឍដទៃទៀត

និរន្តរភាពនៃការអនុវត្តវារីវប្បកម្មទ្រង់ទ្រាយតូចក្នុងបរិបទនៃបរិស្ថានផលិតកម្មបច្ចេកទេសវារីវប្បកម្មគឺមានបង្ហាញនៅក្នុងរូបភាពទី២ ខាងក្រោម (JICA, NACA, DOF 2013 )។ ទោះបីជាស្ថានភាពនៃការអភិវឌ្ឍបែបណាក៏ដោយ កិច្ចការផ្សព្វផ្សាយនេះគឺជាភារកិច្ចរបស់រដ្ឋាភិបាលដែលត្រូវរៀបចំគោលនយោបាយ និងទិសដៅសម្រាប់អភិវឌ្ឍវារីវប្បកម្មទ្រង់ទ្រាយតូច ។ ពាក់ព័ន្ធនឹងសកម្មភាពផ្សព្វផ្សាយវារីវប្បកម្ម ធនធានមនុស្សប្រកបដោយគុណភាពនិងសមត្ថភាពអនុវត្តរបស់រដ្ឋាភិបាលនិងភ្នាក់ងារអភិវឌ្ឍដទៃទៀត គឺជាគន្លឹះយ៉ាងសំខាន់ក្នុងការជម្រុញការផ្សព្វផ្សាយបច្ចេកទេសណាមួយ។ រដ្ឋាភិបាល និងដៃគូអភិវឌ្ឍអាចជម្រុញការអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្មទ្រង់ទ្រាយតូចពីកសិករទៅកសិករ តាមរយៈគោលនយោបាយសមស្រប ការកំណត់នូវទិសដៅត្រូវអនុវត្ត ការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងការកសាងសមត្ថភាពធនធានមនុស្ស។ ជាទូទៅ ការផ្តល់សេវាកម្មទាំងនេះគឺមិនគិតថ្លៃឡើយ ជាពិសេសពាក់ព័ន្ធនឹងការកសាងសមត្ថភាពធនធានមនុស្ស និងភាគច្រើនគឺការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងការគាំទ្រ   បច្ចេកទេស។ ម្យ៉ាងទៀត រដ្ឋាភិបាលក៏មានតួនាទីសំខាន់

ក្នុងការរៀបចំច្បាប់សំខាន់ៗដទៃទៀតដែលពាក់ព័ន្ធនឹងផលិតកម្មវារីវប្បកម្ម ដែលរួមបញ្ចូលសុខភាព និងសុវត្ថិភាពចំណីអាហារផងដែរ។

ចំពោះវគ្គបណ្តុះបណ្តាលនិងការផ្សព្វផ្សាយ រដ្ឋាភិបាលនិងភ្នាក់ងារអភិវឌ្ឍមានតួនាទីក្នុងការផ្តល់នូវវគ្គបណ្តុះបណ្តាល និងណែនាំកសិករផលិតកូនត្រីពូជរហូតដល់ពួកគាត់មានសមត្ថភាពរឹងមាំនិងមានភាពជឿជាក់ខ្លួនឯងក្នុងការផ្ទេរចំណេះដឹង និងផ្សព្វផ្សាយបច្ចេកទេសទៅកសិករដទៃទៀត។ រដ្ឋាភិបាលក៏មានភាពទទួលខុសត្រូវផងដែរក្នុងការអភិវឌ្ឍ ការផលិត និងការចែកផ្សាយសម្ភារៈបណ្តុះបណ្តាលបច្ចេកទេសដែលត្រូវរៀបចំឱ្យមានភាពសាមញ្ញ ងាយស្រួលដល់កសិករងាយយល់និងអនុវត្តបាន។ សម្ភារបណ្តុះបណ្តាលបច្ចេកទេសទាំងនេះអាចជាផ្ទាំងរូបភាព ការថតជាសម្លេង ឬជាសម្ភារៈដទៃទៀតដែលមន្ត្រីផ្សព្វផ្សាយនិងកសិករផលិតកូនត្រីអាចយកទៅផ្សព្វផ្សាយដល់កសិករចិញ្ចឹមត្រីទ្រង់ទ្រាយតូចបាន (ដូចឧទាហរណ៍រូបភាពទី៣ ដែលជាផ្ទាំងរូបភាពបច្ចេកទេសដែលកសិករផលិតកូនត្រីនៅក្នុងប្រទេសកម្ពុជាបានប្រើប្រាស់ក្នុងពេលវគ្គបណ្តុះបណ្តាលបច្ចេកទេស)។ ការជ្រើសរើសនិងបង្កើតកសិដ្ឋានគំរូ គួរអនុវត្តឱ្យមានប្រសិទ្ធភាពផងដែរទៅលើការធ្វើបង្ហាញអំពីការអនុវត្ត ការគ្រប់គ្រងវារីវប្បកម្មល្អ លើផ្នែកផលិតកម្មកូនត្រីពូជនិងចិញ្ចឹមត្រីសាច់។

លើសពីនេះ ផ្នែកខ្សែសង្វាក់ផ្គត់ផ្គង់ផលវារីវប្បកម្មក៏អាចមានតួនាទីសំខាន់ផងដែរក្នុងការផ្តល់សេវាកម្មផ្សព្វផ្សាយបច្ចេកទេស ឧទាហរណ៍ អ្នកផ្គត់ផ្គង់ចំណីត្រី និងសម្ភារៈវារីវប្បកម្មដទៃទៀត ក៏អាចផ្តល់សេវាកម្មបច្ចេកទេសទៅកសិករ តាមរយៈការប្រាស្រ័យទាក់ទងគ្នាជាប្រចាំ។ ម្យ៉ាងទៀតការផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្មក៏អាចអនុវត្តបាននៅថ្នាក់ជាតិ ថ្នាក់មូលដ្ឋាន ឬនៅតាមកសិដ្ឋានវារីវប្បកម្មបានផងដែរ តាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ដែលកសិករអាចងាយ និងទទួលយកបាន ដូចជា(ការផ្សព្វផ្សាយតាមវិទ្យុ ឯកសារបិទផ្សាយជាដើម)។

# ៤. ភារកិច្ចរបស់មន្ត្រីផ្សព្វផ្សាយរបស់រដ្ឋាភិបាល

ដើម្បីជម្រុញការផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្មទឹកសាបទ្រង់ទ្រាយតូចឱ្យបានដល់សហគមន៍ (JICA and FiA, 2014 ) ជាពិសេសនៅក្នុងតំបន់ជនបទ មន្ត្រីផ្សព្វផ្សាយរបស់រដ្ឋាភិបាលដែលទទួលខុសត្រូវលើការអភិវឌ្ឍវារីវប្បកម្មគួរមានភារកិច្ចដូចខាងក្រោម ៖

១. ផ្តល់ការណែនាំបច្ចេកទេសដល់កសិករចិញ្ចឹមត្រីអំពីចំណេះដឹងជាមូលដ្ឋាន និងជំនាញវារីវប្បកម្មទឹកសាបទ្រង់ទ្រាយតូច តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងដឹកនាំទស្សនកិច្ចសិក្សា។ កសិករចិញ្ចឹមត្រី អាចមិនទាន់មានការចូលរួមក្នុងការអនុវត្តជាក់ស្តែងភ្លាមៗនោះទេ ដូចនេះការចុះតាមដាននូវសកម្មភាពចូលរួមរបស់កសិករគួរតែត្រូវធ្វើឡើងដើម្បីលើកទឹកចិត្តកសិករឱ្យចូលរួមក្នុងសកម្មភាពចិញ្ចឹមត្រីឱ្យបានកាន់តែខ្លាំងឡើងថែមទៀត។

២. ចុះត្រួតពិនិត្យដល់ទីកន្លែងនូវស្ថានភាពវារីវប្បកម្ម និងដំណើរការកសិដ្ឋានឱ្យបានពី ១ទៅ ២ដង ក្នុង១ខែ។ ការចុះត្រួតពិនិត្យសកម្មភាពនេះនឹងជួយដាស់តឿន និងលើកទឹកចិត្តដល់កសិករឱ្យនៅតែបន្តសកម្មភាពវារីវប្បកម្មរបស់ពួកគាត់។

៣. ចុះប្រមូលនិងផ្សព្វផ្សាយព័ត៌មាន ជាពិសេសព័ត៌មានអំពីការអភិវឌ្ឍថ្មីៗ ឬព័ត៌មានពាក់ព័ន្ធនឹងបច្ចេកទេសវារីវប្បកម្ម ដើម្បីជួយកែលំអបច្ចេកទេសវារីវប្បកម្មរបស់កសិករឲ្យបានកាន់តែប្រសើរឡើង។នេះជាសកម្មភាពផ្សព្វផ្សាយមួយយ៉ាងសំខាន់នៅក្នុងតំបន់ជនបទដាច់ស្រយាល ដែលកសិករតែងតែខ្វះការទទួលបាននូវព័ត៌មានថ្មីៗ និងបញ្ហាផ្សេងៗទៀតដែលពាក់ព័ន្ធនឹងវារីវប្បកម្ម។

៤. គាំទ្រដល់ការចែកចាយកូនត្រីពូជ ដោយបង្កើតជាបណ្តាញទីផ្សាររវាងកសិករផលិតកូនត្រីនិងកសិករចិញ្ចឹមត្រី។ សកម្មភាពនេះនឹងជួយសម្របសម្រួលឱ្យមានតុល្យភាពរវាងការផ្គត់ផ្គង់នឹងតម្រូវការកូនត្រី ហើយជៀសវាងនូវការផលិតកូនត្រីច្រើនហួសដែលនាំមកនូវការខ្ជះខ្ជាយនិងខាតបង់ ។

៥. បង្កើតបណ្តាញទំនាក់ទំនងរវាងរដ្ឋាភិបាលថ្នាក់ជាតិ ថ្នាក់ខេត្ត ជាមួយនឹងដៃគូរអភិវឌ្ឍ និងអាជ្ញាធរមូលដ្ឋានដែលកសិកររស់នៅ ដើម្បីគាំទ្រនឹងសម្របសម្រួលយន្តការផ្សព្វផ្សាយវារី

វប្បកម្មនេះឱ្យមានប្រសិទ្ធភាព។ មានការកត់សំគាល់ថា អាជ្ញាធរមូលដ្ឋានមានព័ត៌មានសមស្រប ដែលជាតម្រូវការចាំបាច់របស់សហគមន៍ ឬមានភាពសមស្របបំផុតសម្រាប់អនុវត្តសកម្មភាពផ្សព្វផ្សាយ ។

៦. គាំទ្រដល់បណ្តាញកសិករផលិតកូនត្រីពូជ ដែលទទួលខុសត្រូវលើសកម្មភាពផ្សព្វផ្សាយព័ត៌មាន និងបច្ចេកទេសវារីវប្បកម្មនៅថ្នាក់មូលដ្ឋានផ្ទាល់។

៧. ភារកិច្ចទាំងអស់ដែលបានបញ្ជាក់ខាងលើនេះ គួរតែត្រូវអនុវត្តដោយមានកិច្ចសហប្រតិបត្តិការជាមួយនឹងបណ្តាញកសិករផលិតកូនត្រីពូជ ដែលជាភ្នាក់ងារផ្សព្វផ្សាយយ៉ាងសំខាន់នៅមូលដ្ឋាន ដើម្បីទទួលបានការផ្សព្វផ្សាយល្អនិងមានប្រសិទ្ធភាពកាន់តែខ្លាំងឡើងថែមទៀត ។

# ៥. ការជ្រើសរើសកសិករផលិតកូនត្រី និងផ្តល់វគ្គបណ្តុះបណ្តាល

## ការជ្រើសរើសកសិករផលិតកូនត្រី

បញ្ហាសំខាន់មួយក្នុងចំណោមបញ្ហាសំខាន់នានា ក្នុងការអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយវារីវប្បកម្មពីកសិករទៅកសិករ ឬទៅក្រុមកសិករដទៃទៀត គឺការជ្រើសរើសកសិករម្នាក់ៗដែលមានជំនាញពិតប្រាកដ ហើយបានទទួលស្គាល់ពីក្រុមកសិករក្នុងសហគមន៍ ដើម្បីក្លាយជាកសិករផលិតកូនត្រីមានប្រសិទ្ធភាព និងមានសមត្ថភាពបង្រៀនបច្ចេកទេសទៅកសិករដទៃទៀត។ ការជ្រើសរើសកសិករផលិតកូនត្រី គឺមានបង្ហាញនៅក្នុងរូបភាពទី៣ (JICA, NACA, DOF 2013 )។ កសិករផលិតកូនត្រីមានតួនាទីយ៉ាងសំខាន់និងចាំបាច់ក្នុងសកម្មភាពផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្ម និងការគ្រប់គ្រងបណ្តាញកសិករឱ្យប្រសើរឡើង។ ពួកគាត់ក៏មានតួនាទីក្នុងការផ្តល់នូវវគ្គបណ្តុះបណ្តាលបច្ចេកទេសដល់កសិករចិញ្ចឹមត្រី និងកសិករផលិតកូនត្រីដែលជារឿយៗពួកគាត់បានបំពេញតួនាទីនេះបានច្រើនជាងមន្ត្រីផ្សព្វផ្សាយរដ្ឋាភិបាល។ ដូចនេះ ការជ្រើសរើសកសិករផលិតកូនត្រីឱ្យបានត្រឹមត្រូវ គឺពិតជាមានសារៈសំខាន់ ដោយត្រូវអនុ

វត្តតាមលក្ខណៈវិនិច្ឆ័យដើម្បីធានាបាននូវការផ្សព្វផ្សាយព័ត៌មាន បច្ចេកទេសវារីវប្បកម្ម និងលទ្ធផលនៃការអនុវត្តសកម្មភាពវារីវប្បកម្មតាមកសិដ្ឋានឱ្យមានប្រសិទ្ធភាព។ លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសកសិករផលិតកូនត្រីគួរតែរៀបចំឱ្យបានត្រឹមត្រូវនិងប្រយ័ត្នប្រយែងដើម្បីបង្កើននូវលទ្ធភាពដែលអាចទទួលបាននូវភាពជោគជ័យជាច្រើននៅក្នុងកម្មវិធីផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្ម ។ ខាងក្រោមនេះគឺជាឧទាហរណ៍អំពីលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសកសិករផលិតកូនត្រីដែលបានអនុវត្តនៅក្នុងប្រទេសកម្ពុជា (Viseth et al., 2013 )៖

១. មានជំនាញ និងបទពិសោធន៍ចិញ្ចឹមត្រី ឬផលិតកូនត្រីបានខ្លះៗ
២. មានមធ្យោបាយសម្ភារមួយចំនួន ដូចជា (ពូជត្រី និង ឬ ត្រីសាច់ )
៣. មានប្រភពទឹក
៤. មានសេដ្ឋកិច្ចក្នុងគ្រួសារល្អ
៥. មានបំណងចង់ក្លាយជាកសិករផលិតកូនត្រីពូជ (និងមានបទពិសោធន៍ផ្សព្វផ្សាយ) ។

*បណ្ដាញកសិករផលិតកូនត្រីនៅក្នុងបណ្ដាខេត្តនានា នៃប្រទេសកម្ពុជាដែលគម្រោងបង្កើនផលិតភាពនិងផ្សព្វផ្សាយវារីវប្បកម្មទឹកសាបឧបត្ថម្ភដោយអង្គការយ៉ៃកា JICA បានអនុវត្ត ក្នុងដំណាក់កាលទី ១និងដំណាក់កាលទី ២ បានអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយពីកសិករទៅកសិករយ៉ាងសកម្មសម្រាប់ការអភិវឌ្ឍវារីវប្បកម្មទឹកសាបទ្រង់ទ្រាយតូច។ សមាជិកនៃបណ្ដាញកសិករផលិតកូនត្រីក្នុងខេត្តកំពត តាកែវ ពោធិសាត់ និងខេត្តបាត់ដំបង បានកត់ត្រាទុកនូវផលប្រយោជន៍ ដូចខាងក្រោម ដែលកសិករដទៃទៀតអាចទាក់ទង និង រៀនសូត្រជាបទពិសោធន៍ សម្រាប់ជាគុណប្រយោជន៍របស់ខ្លួនបាន៖*

- *កម្ចីថវិកាសម្រាប់សាងសង់អាងបង្កាត់ ភ្ញាស់ និងដំណើរការផលិតកម្មកូនត្រី និងចិញ្ចឹមត្រី (គ្រប់សមាជិកក្នុងបណ្ដាញត្រូវសងប្រាក់កម្ចីចូលក្នុងបណ្ដាញវិញជាមួយការប្រាក់បន្តិចបន្តួច )*
- *ចែករំលែកការផ្គត់ផ្គង់កូនត្រី និងបណ្ដាញទីផ្សារ*
- *ចែករំលែកធនធានដទៃទៀត (ដូចជា អ័កម៉ូនសម្រាប់ចាក់ត្រីមេពូជ ) ។*

*បណ្ដាញកសិករផលិតកូនត្រីក៏បានរៀបចំការជួបប្រជុំគ្នារៀងរាល់ ៣ទៅ ៤ខែម្ដង ឬក៏រក្សាការទំនាក់ទំនងគ្នាតាមទូរស័ព្ទ ឬតាមការផ្ញើសារតាមទូរស័ព្ទ។*



*Mrs. Set Thy, President*
*CF Network*
*Kampot Province*



*Mr.Van Po, President*
*CF Network*
*Takeo Province*



**រូបភាពទី ៤៖** មន្ត្រីផ្សព្វផ្សាយរដ្ឋាភិបាលផ្តល់នូវការណែនាំនិងសម្របសម្រួលដល់កសិករផលិតកូនត្រីក្នុងការរៀបចំបង្កើតក្រុមបណ្តាញកសិករ (រូបថតផ្តល់ដោយរដ្ឋបាលជលផល ប្រទេសកម្ពុជា )

ជាលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសកសិករផលិតកូនត្រីដូចខាងលើគឺអាចបត់បែនបាន អាស្រ័យទៅនឹងស្ថានភាពវារីវប្បកម្មទ្រង់ទ្រាយតូចនៅក្នុងតំបន់ ឬនៅក្នុងប្រទេសនោះ ហើយ និងសមត្ថភាពបច្ចុប្បន្នរបស់កសិករចិញ្ចឹមត្រី។ ឧទាហរណ៍ ប្រទេសអភិវឌ្ឍច្រើនដែលមានការអភិវឌ្ឍប្រព័ន្ធវារីវប្បកម្មល្អ ទំនើប គួរតែមានលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសកសិករផលិតកូនត្រីឲ្យបានជាក់លាក់បំផុត ដែលអាចផ្សព្វផ្សាយនិងពង្រីកបច្ចេកទេសវារីវប្បកម្មទៅកសិករចិញ្ចឹមត្រីទ្រង់ទ្រាយតូចដទៃៗទៀតបាន។ តួនាទីរបស់រដ្ឋាភិបាលនិងដៃគូរអភិវឌ្ឍគឺផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេស និងចុះពិនិត្យសកម្មភាពវារីវប្បកម្មរបស់កសិករផលិតកូនត្រី រហូតដល់ពេលដែលពួកគាត់មានសមត្ថភាពបច្ចេកទេស និងមានទំនុកចិត្តគ្រប់គ្រាន់ក្នុងការព្វផ្សាយបច្ចេកទេសទៅកសិករដទៃទៀត។ ដូចនេះកសិករផលិតកូនត្រីដែលបានជ្រើសរើសហើយ គួរមានឆន្ទៈនិងការប្តេជ្ញាចិត្តអនុវត្តរួមគ្នាជាមួយភ្នាក់ងារផ្សព្វផ្សាយរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ក្នុងការអនុវត្តសកម្មភាពផ្សព្វផ្សាយវារីវប្បកម្មឱ្យបានជោគជ័យ។

## ការផ្ដល់វគ្គបណ្តុះបណ្តាល

ការផ្ដល់នូវវគ្គបណ្ដុះបណ្ដាលបច្ចេកទេសសម្រាប់កសិករផលិតកូនត្រីពូជ គឺជាការទទួលខុសត្រូវរបស់មន្ត្រីផ្សព្វផ្សាយវារីវប្បកម្មរបស់រដ្ឋាភិបាលដែលមានបទពិសោធន៍ និងបានទទួលការបំពាក់បំប៉នបច្ចេកទេសវារីវប្បកម្មរួចហើយ។ វគ្គបណ្ដុះបណ្ដាលនេះគួររៀបចំសម្រាប់កសិករផលិតកូនត្រី ដើម្បីជួយឱ្យកសិករអាចគ្រប់គ្រងកសិដ្ឋានរបស់ខ្លួនប្រកបដោយនិរន្តភាព (ជាកសិដ្ឋានផលិតកូនត្រី ឬចិញ្ចឹមត្រីសាច់) និងដើម្បីធ្វើជាគំរូសម្រាប់បង្ហាញដល់កសិករទ្រង់ទ្រាយតូចឱ្យមានការចាប់អារម្មណ៍ នៅពេលដែលយុទ្ធសាស្ត្រផ្សព្វ ផ្សាយពីកសិករទៅកសិករត្រូវបានអនុវត្ត។ ដោយហេតុថា បទពិសោធន៍និងសមត្ថភាពផ្សព្វផ្សាយរបស់កសិករផលិតកូនត្រីមានភាពខុសៗគ្នា ដូចនេះកម្មវិធីវគ្គបណ្ដុះបណ្ដាលបច្ចេកទេសមួយចំនួនដែលត្រូវផ្ដល់ឱ្យកសិករ គួររៀបចំឡើងឱ្យបានស្របតាមតម្រូវការ បទពិសោធន៍ និងសមត្ថភាពជំនាញបច្ចេកទេសរបស់ពួកគាត់។ ខាងក្រោមនេះគឺជាឧទាហរណ៍នៃកម្មវិធីវគ្គបណ្ដុះបណ្ដាលបច្ចេកទេសសម្រាប់កសិករផលិតកូនត្រីដែលទើបនឹងចាប់ផ្ដើម និងកសិករដែលមានបទពិសោធន៍ច្រើនមកហើយ (កែសម្រួលពីកម្មវិធីវគ្គបណ្ដុះបណ្ដាលបច្ចេកទេសដែលបានរៀបចំដោយរដ្ឋបាលជលផលនៃប្រទេសកម្ពុជា សម្រាប់មន្ត្រីផ្សព្វផ្សាយ និងកសិករផលិតកូនត្រីដែលមានសមត្ថភាពបច្ចេកទេសកម្រិតដំបូង និងកម្រិតខ្ពស់ FiA and JICA, 2014 )។

- *កម្មវិធីវគ្គបណ្តុះបណ្តាលបច្ចេកទេសសម្រាប់កម្រិតដំបូង*
    - សិក្ខាកាម៖ កសិករផលិតកូនត្រីថ្មី (ជាកសិករដែលទើបនឹងចាប់ផ្ដើមផលិតកូនត្រី ឬផលិតត្រីសាច់ )
    - ប្រធានបទ៖ បច្ចេកទេសវារីវប្បកម្មជាមូលដ្ឋាន  បច្ចេកទេសផលិតកូនត្រី និងវិធីសាស្ត្រផ្សព្វផ្សាយ
    - វិធីសាស្ត្របង្រៀន៖ ការបង្រៀនត្រូវមានភាពសាមញ្ញងាយយល់ វគ្គបណ្ដុះបណ្ដាលមានភ្ជាប់ជាមួយការអនុវត្តជាក់ស្ដែង និងផ្ដល់ទស្សនកិច្ចសិក្សា
    - លទ្ធផលរំពឹងទុក៖ បង្កើនលទ្ធភាពក្នុងការផ្ដល់ដំបូន្មានបច្ចេកទេសផលិតកូនត្រី និងចិញ្ចឹមត្រីបានត្រឹមត្រូវដល់កសិករ ។
- *កម្មវិធីវគ្គបណ្តុះបណ្តាលបច្ចេកទេសសម្រាប់កម្រិតខ្ពស់*

- សិក្ខាកាម ៖ កសិករផលិតកូនត្រីមានបទពិសោធន៍ (ទាំងផលិតកូនត្រី និងចិញ្ចឹមត្រីសាច់)
- ប្រធានបទ ៖ បច្ចេកទេសវារីវប្បកម្មថ្មីៗ ដូចជាបច្ចេកទេសផលិតកូនត្រី ការគ្រប់គ្រងកសិដ្ឋានល្អ និងការរៀបចំផែនការនានា
- វិធីសាស្ត្របង្រៀន៖ ផ្តល់ឯកសារមេរៀនបច្ចេកទេសផលិតកូនត្រី និងការគ្រប់គ្រងកសិដ្ឋានល្អ និងផ្តល់ទស្សនកិច្ចសិក្សា
- លទ្ធផលរំពឹងទុក ៖ សមត្ថភាពក្នុងការផ្តល់សេវាកម្មផ្សព្វផ្សាយមានភាពប្រសើរឡើង ដូចជា ការផ្តល់ដំបូន្មានបច្ចេកទេសផលិតកូនត្រី និងចិញ្ចឹមត្រីសាច់ទៅកសិករចិញ្ចឹមត្រី សេវាកម្មផ្សព្វផ្សាយត្រូវបានពង្រីកពីថ្នាក់មូលដ្ឋាន ដល់ថ្នាក់ខេត្ត និងបង្កើនលទ្ធភាពលើកទឹកចិត្តដល់កសិករដទៃទៀតឱ្យក្លាយទៅជាកសិករផលិតកូនត្រីពូជដោយខ្លួនឯង ។

ការផ្សព្វផ្សាយដល់កសិករចិញ្ចឹមត្រីទ្រង់ទ្រាយតូច គួរតែមានលក្ខណៈសាមញ្ញ ងាយអនុវត្តទាំងបច្ចេកទេសនិងការគ្រប់គ្រងកសិដ្ឋាន ដូចនេះវគ្គបណ្តុះបណ្តាលបច្ចេកទេសសម្រាប់កសិករផលិតកូនត្រីគួររៀបចំឱ្យមានចំនុចសំខាន់ដូចគ្នា។ ជាពិសេស ការបណ្តុះបណ្តាលនិងការងារផ្សព្វផ្សាយគួរដោះស្រាយបាននូវបញ្ហាសំខាន់ៗដូចខាងក្រោម ៖

- ការជ្រើសរើសទីតាំងកសិដ្ឋាន និងស្រះឲ្យបានល្អ
- បច្ចេកទេសរៀបចំស្រះ និងកសិដ្ឋាន
- ការអនុវត្តល្អក្នុងផលិតកម្មកូនត្រីមេៀនិងកូនត្រីពូជ
- ការអនុវត្តល្អក្នុងការដាក់កូនត្រីចិញ្ចឹម
- គុណភាពទឹកល្អ និងការគ្រប់គ្រងចំណី (ប្រសិនបើអាចអនុវត្តបាន) និង
- ការប្រើប្រាស់ទុនតិច ទទួលបានផលខ្ពស់ ។

ម្យ៉ាងទៀត ការផ្លាស់ប្តូរដំណើរទស្សនកិច្ចនៅកសិដ្ឋានដោយផ្ទាល់ គឺជាវិធីមួយដ៏ល្អ និងមានប្រយោជន៍ដើម្បីចែករំលែកបទពិសោធន៍ បញ្ហាជួបប្រទះ ព្រមទាំងបបច្ចេកទេសវារីវប្បកម្មនានាក្នុងចំណោមកសិករដែលបានចូលរួមទាំងអស់។ វិធីផ្សព្វផ្សាយនេះជាធម្មតាគឺមានភាពងាយស្រួលសម្រាប់កសិករក្នុងការទទួលបាននូវព័ត៌មាន ឬបច្ចេកទេសតាមរយៈកិច្ចពិភាក្សាជាមួយ

ក្រុមកសិករក្នុងពេលទស្សនៈកិច្ចសិក្សា។ ជាទូទៅ កសិករដែលបានចូលរួមទស្សនកិច្ចសិក្សានេះ បានជម្រុញទឹកចិត្តគាត់ចង់ចូលរួមសកម្មភាពវារីវប្បកម្មនៅពេលដែលគាត់បានឃើញផ្ទាល់ភ្នែកនូវភាពជោគជ័យនៃសកម្មភាពផលិតកូនត្រី ឬចិញ្ចឹមត្រី ហើយគាត់នឹងបន្តសិក្សាស្វែងយល់ រៀនសូត្របច្ចេកទេសដោយខ្លួនគាត់បន្ថែមទៀតពីកសិករដែលធ្វើបានជោគជ័យនេះ។ ដោយសារ កសិករមានឱកាសបានជជែកពិភាក្សាជាមួយគ្នា ដូចនេះការផ្ទេរចំណេះដឹងបច្ចេកទេស និងព័ត៌មានដល់កសិករតាមរយៈទស្សនកិច្ចសិក្សាគឺមានប្រសិទ្ធភាពខ្ពស់។

# ៦. បណ្តាញកសិករផលិតកូនត្រី

ដូចបានបញ្ជាក់ខាងលើ សកម្មភាពទំនាក់ទំនងពីកសិករទៅកសិករជាទូទៅគឺមានប្រសិទ្ធភាពខ្ពស់ក្នុងការផ្ទេរព័ត៌មាននិងបទពិសោធន៍បច្ចេកទេសពីកសិករទៅកសិករ ជាពិសេសគឺដោះស្រាយបាននូវរាល់បញ្ហាបច្ចេកទេសបង្កាត់ ភ្ញាស់ និងឬការគ្រប់គ្រងស្រះចិញ្ចឹមត្រី ។ នេះជាយុទ្ធសាស្ត្រផ្សព្វផ្សាយដែលតម្រង់ឆ្ពោះទៅលើមុខរបរជំនួញវារីវប្បកម្មយ៉ាងមានប្រសិទ្ធភាព។ ដូចនេះ ការរៀបចំបង្កើតបណ្តាញកសិករផលិតកូនត្រីពូជគឺជាការចាំបាច់ ដើម្បីជួយឱ្យក្រុមកសិករអាចបន្តធ្វើការទាក់ទងនិងរៀនសូត្រពីគ្នាទៅវិញទៅមកបាន។ មន្ត្រីផ្សព្វផ្សាយរបស់រដ្ឋាភិបាលដែលបានទទួលការបណ្តុះបណ្តាលជំនាញបច្ចេកទេសវារីវប្បកម្ម អាចជួយរៀបចំបង្កើតបណ្តាញកសិករផលិតកូនត្រីពូជ និងជួយក្រុមកសិករអំពីរបៀបបង្កើត និងគ្រប់គ្រងក្រុមបណ្តាញកសិករ (រូបភាពទី៤ ) ។

ដំណើរការរៀនសូត្រនេះ អាចធ្វើឡើងជាផ្លូវការ ឬក៏មិនផ្លូវការ ស្របទៅនឹងស្ថានភាពមូលដ្ឋានតាមរយៈសកម្មភាពប្រជុំ វគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានា។

ខាងក្រោមនេះជាផលប្រយោជន៍ដែលរំពឹងទុកមួយចំនួនដែលក្រុមបណ្តាញកសិករផលិតកូនត្រីពូជនឹងផ្តល់ដល់សមាជិកកសិករផលិតកូនត្រីពូជទាំងអស់ រួមទាំងកសិករចិញ្ចឹមត្រីទ្រង់ទ្រាយតូចដែលចូលរួមក្នុងការងារផ្សព្វផ្សាយ ៖

*កសិករផលិតកូនត្រីក្នុងប្រទេសកម្ពុជា បានអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយពីកសិករទៅកសិករទទួលបានជោគជ័យ ហើយបានធ្វើការបណ្តុះបណ្តាលបច្ចេកទេសទៅកសិករទាំងបុរសនិងស្ត្រីបានរាប់ពាន់នាក់ក្នុងរយៈពេលអនុវត្តគម្រោងបង្កើនផលិតភាពនិងផ្សព្វផ្សាយវារីវប្បកម្មទឹកសាបដែលឧបត្ថម្ភដោយអង្គការជ៉ៃកា JICA ទាំង២ដំណាក់កាល (សរុបក្នុងរយៈពេល ៩ឆ្នាំ )។ លោកស្រី សៃត ធី ជាកសិករផលិតកូនត្រីក្នុងខេត្តកំពតបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីដល់កសិករជាង១០០០នាក់ ដែលភាគច្រើននៃកសិករទាំងនោះបានយកចំណេះដឹងពីការបណ្តុះបណ្តាលទៅធ្វើការចិញ្ចឹមត្រីទទួលបានជោគជ័យ។ កសិករឈ្មោះ វ៉ាន់ ប៉ូ ជាកសិករផលិតកូនត្រីក្នុងខេត្តតាកែវ និងកសិករឈ្មោះ ជិន គន្ធី ជាកសិករផលិតកូនត្រីក្នុងខេត្តពោធិសាត់ កសិករម្នាក់ៗបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីដល់កសិករពី ៦០០ ទៅ ៧០០ នាក់។ ក្រោយពីវគ្គបណ្តុះបណ្តាល កសិករចិញ្ចឹមត្រីប្រមាណពី ៧០ ទៅ ៨០% ក្នុងខេត្តតាកែវធ្វើការចិញ្ចឹមត្រីទទួលបានជោគជ័យ ដោយឡែកចំពោះកសិករចិញ្ចឹមត្រីក្នុងខេត្តពោធិសាត់ គឺមានប្រមាណតែពី ៤០ ទៅ ៥០% ប៉ុណ្ណោះដែលលបានធ្វើការចិញ្ចឹមត្រីទទួលជោគជ័យ ដោយសារតែភាពរាំងស្ងួតធ្វើឱ្យខ្វះទឹក។ កសិករផលិតកូនត្រីនៅខេត្តបាត់ដំបងឈ្មោះ មិត្ត ផាន់ បានធ្វើការបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីដល់កសិករប្រមាណ ៤០០នាក់ ហើយមានកសិករប្រមាណពី២៥ ទៅ ៣០% ធ្វើការចិញ្ចឹមត្រីទទួលបានជោគជ័យ។*

*មានការបញ្ជាក់ថា មិនមែនគ្រប់កសិករដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលសុទ្ធតែជាកសិករមានបទពិសោធន៍ចិញ្ចឹមត្រីទាំងអស់គ្នានោះទេ។ មានកសិករខ្លះគ្រាន់តែជាសមាជិកក្នុងសហគមន៍ដែលមានការចាប់អារម្មណ៍ចង់ទទួលបានចំណេះដឹងបច្ចេកទេសចិញ្ចឹមត្រីប៉ុណ្ណោះ។ វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីគឺភាគច្រើនត្រូវបានអនុវត្តនៅក្នុងឃុំគោលដៅ ប៉ុន្តែក៏មានកសិករផលិតកូនត្រីខ្លះបានបង្រៀនបច្ចេកទេសចិញ្ចឹមត្រីនេះទៅកសិករនៅឃុំ និងខេត្តដទៃទៀតផងដែរ។ គ្រប់វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីនេះគឺបានបើកចំហឱ្យកសិករទាំងបុរសនិងស្ត្រីចូលរួម ។*

- កែលំអជំនាញបច្ចេកទេសផលិតកម្មកូនត្រីពូជ
- មានសមត្ថភាពលក់ និងចែកចាយកូនត្រីពូជ
- សម្របសម្រួលនិងស្នើសុំជំនាញបច្ចេកទេស ឬហិរញ្ញវត្ថុ តាមតម្រូវការ
- ចែករំលែកបញ្ហាជួបប្រទះនិងដំណោះស្រាយពីការគ្រប់គ្រងស្រះ និងអាងបង្កាត់ ភ្ញាស់
- ស្វែងរកទីផ្សារ និងបណ្តាញទីផ្សារលក់ផលិតផលវារីវប្បកម្ម
- សម្របសម្រួលជួយដល់ការអនុវត្តបច្ចេកទេសចិញ្ចឹមដល់កសិករ
- មានកម្លាំងរួមគ្នាខ្លាំងក្លាក្នុងការចចារ និងដោះស្រាយបញ្ហា ។

នៅពេលដែលបណ្តាញកសិករផលិតកូនត្រីត្រូវបានបង្កើតឡើងហើយ ភ្នាក់ងាររដ្ឋាភិបាលថ្នាក់ជាតិ ឬថ្នាក់មូលដ្ឋានគួរជួយឧបត្ថម្ភគាំទ្រពេញលេញចំពោះសេវាកម្មផ្សព្វផ្សាយបច្ចេកទេសវារី

វប្បកម្ម។ បណ្តាញកសិករផលិតកូនត្រីគួរបោះឆ្នោតជ្រើសរើសសមាជិកគ្រប់គ្រងដូចជា ប្រធាន អនុប្រធាន  លេខាធិកា និងហិរញ្ញិក និងរៀបចំចងក្រងជាលក្ខន្តិកៈសមស្រប ដើម្បីឱ្យបណ្តាញអាចមានដំណើរការបានល្អ និងមាននិរន្តរភាព។

# ៧. ការផ្សព្វផ្សាយពីកសិករទៅកសិករ

យុទ្ធសាស្ត្រផ្សព្វផ្សាយពីកសិករទៅកសិករ គឺអាចជួយឱ្យក្រុមកសិករផលិតកូនត្រីធ្វើការបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីដល់កសិករក្នុងសហគមន៍បាន ដោយប្រើប្រាស់សម្ភារបង្រៀន និងផ្សព្វផ្សាយដែលរៀបចំនៅមូលដ្ឋានសម្រាប់បង្រៀននិងផ្សព្វផ្សាយដល់កសិករនៅក្នុងមូលដ្ឋាន។ ដូចនេះ កសិករផលិតកូនត្រីត្រូវតែរៀនជំនាញបណ្តុះបណ្តាលជាមូលដ្ឋាន ដើម្បីមានចំណេះដឹងបច្ចេកទេសនិងមានសមត្ថភាពបង្រៀនដូចជាគ្រូបង្រៀន (រដ្ឋបាលជលផលនិងអង្គការយ៉ៃកា ឆ្នាំ២០១៤)។ ក្រុមមន្ត្រីផ្សព្វផ្សាយបច្ចេកទេសរបស់រដ្ឋាភិបាលនឹងទទួលខុសត្រូវផ្តល់នូវការបណ្តុះបណ្តាលដល់កសិករផលិតកូនត្រីអំពីជំនាញក្នុងការបង្រៀន និងផ្តល់សម្ភារបណ្តុះបណ្តាលដូចជា សៀវភៅ ផ្ទាំងរូបភាព និងវីដេអូអំពីបច្ចេកទេសវារីវប្បកម្ម ដែលក្រុមកសិករផលិតកូនត្រីនឹងយកទៅបង្រៀននិងផ្សព្វផ្សាយបន្តដល់កសិករដទៃទៀត។ មន្ត្រីផ្សព្វផ្សាយបច្ចេកទេសរបស់រដ្ឋាភិបាលគួររៀបចំកសិដ្ឋានគំរូសម្រាប់ធ្វើបង្ហាញបច្ចេកទេសផលិតកម្មកូនត្រីនិងចិញ្ចឹមត្រីយកសាច់ សម្រាប់កសិករផលិតកូនត្រីពូជ រៀនសូត្រនិងអនុវត្តតាម (រូបភាពទី ៥) ។

នៅក្នុងវគ្គបណ្តុះបណ្តាលបច្ចេកទេសពីកសិករទៅកសិករ កសិករផលិតកូនត្រីត្រូវបង្រៀនជំនាញជាមូលដ្ឋានអំពីបច្ចេកទេសចិញ្ចឹមត្រីទៅដល់កសិករដទៃទៀតដែលចូលរួមជម្រុញសកម្មភាពវារីវប្បកម្មឱ្យមានទំនាក់ទំនងជិតស្និទ្ធរវាងកសិករផលិតកូនត្រីនិងកសិករចិញ្ចឹមត្រី។ ទំនាក់ទំនងដ៏ល្អប្រសើរនេះនឹងជួយសម្របសម្រួលយ៉ាងមានប្រសិទ្ធភាពនូវការផ្គត់ផ្គង់និងចែកចាយកូនត្រីពូជដែលជាតម្រូវការចាំបាច់សម្រាប់ដាក់ចិញ្ចឹម និងជួយផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រីដល់កសិករថែមទៀតផង។



**រូបភាពទី ៥៖** វគ្គបណ្តុះបណ្តាលតាមរយៈការអនុវត្តជាក់ស្តែងអំពីជំនាញជាមូលដ្ឋាន និងបច្ចេកទេសផលិតកម្មកូនត្រីពូជ ត្រូវបានធ្វើឡើងនៅពេលអនុវត្តសកម្មភាពផ្សព្វផ្សាយ (រូបថតផ្តល់ដោយរដ្ឋបាលជលផល ប្រទេសកម្ពុជា )



**រូបភាពទី ៦៖** វគ្គបណ្តុះបណ្តាលរបស់កសិករចិញ្ចឹមត្រី ដែលបង្រៀនដោយកសិករផលិតកូនត្រីពូជ (រូបថត ផ្តល់ដោយរដ្ឋបាលជលផល ប្រទេសកម្ពុជា )

កសិករផលិតកូនត្រីក៏អាចពង្រីកការបណ្តុះបណ្តាលបច្ចេកទេសផលិតកូនត្រីដល់កសិករដទៃទៀតដែលចង់ក្លាយជាកសិករចេះផលិតកូនត្រីពូជដោយខ្លួនឯងបាន។ ក្នុងករណីនេះ កសិករផលិតកូនត្រីនឹងបង្ហាត់បង្រៀនដល់កសិករដទៃទៀតអំពីចំណេះដឹងបច្ចេកទេសជំនាញជាមូលដ្ឋាននៃការផលិតកូនត្រី និងណែនាំអំពីវិធីដែលអាចក្លាយជាកសិករផលិតកូនត្រីពូជនៅពេលអនាគតបាន។

ដូចបង្ហាញក្នុងរូបភាពទី១ កសិករចិញ្ចឹមត្រី និងកសិករផលិតកូនត្រីដែលបានទទួលការបណ្តុះបណ្តាលបច្ចេកទេសរួចហើយ គឺគួរលើកទឹកចិត្តឱ្យពួកគាត់ចូលរួមចែករំលែកបទពិសោធន៍ទៅកសិករដទៃទៀតនៅក្នុងមូលដ្ឋាន និងនៅក្រៅតំបន់របស់ខ្លួនផងដែរ។ នេះជាការពង្រីកចំណេះដឹងបច្ចេកទេសវារីវប្បកម្មបន្តទៀត និងលើកទឹកចិត្តកសិករនៅក្នុងសហគមន៍ដទៃទៀតដែលចាប់អារម្មណ៍ឱ្យចូលរួមសកម្មភាពចិញ្ចឹមត្រី និង  ផលិតកូនត្រីពូជ (រូបភាពទី ៦) ។

វគ្គបណ្តុះបណ្តាលបច្ចេកទេសសម្រាប់កសិកររួមមានដូចខាងក្រោម ៖

> *នៅប្រទេសឡាវ យុទ្ធសាស្ត្រផ្សព្វផ្សាយពីកសិករទៅកសិករត្រូវបានអនុវត្តតាមរយៈគម្រោងផ្សព្វផ្សាយ និងកែលម្អបច្ចេកទេសវារីវប្បកម្មដំណាក់កាលទី ២ ចាប់ពីឆ្នាំ ២០០៥ ដល់ឆ្នាំ២០១០ ។ កសិករផលិតកូនត្រីដែលបានទទួលការបណ្តុះបណ្តាលបច្ចេកទេសមិនត្រឹមតែបានអនុវត្តការផលិតកូនត្រី និងចិញ្ចឹមត្រីសាច់សម្រាប់ខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែក៏បានបង្រៀនបច្ចេកទេសចិញ្ចឹមត្រីទៅកសិករដទៃទៀតផងដែរ ។*
> *នៅប្រទេសប៉េនីន គម្រោងផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្មទឹកសាបបានឧបត្ថម្ភគាំទ្របច្ចេកទេសដល់កសិករណាដែលមានលទ្ធភាពអាចផលិតកូនត្រី និងចំណីត្រី។ ក្នុងរយៈពេល៣ឆ្នាំកន្លះនៃការអនុវត្តគម្រោង កសិករចិញ្ចឹមត្រីទាំងបុរសនិងស្ត្រីចំនួន ២,២០០ នាក់បានទទួលការបណ្តុះបណ្តាលបច្ចេកទេសពីកសិករផលិតកូនត្រី ហើយនេះជាការឆ្លុះបញ្ចាំងថាយុទ្ធសាស្ត្រផ្សព្វផ្សាយបច្ចេកទេសនេះត្រូវបានអនុវត្តដោយទទូលបាននូវប្រសិទ្ធភាព តាមរយៈសកម្មភាពបណ្តុះបណ្តាលបច្ចេកទេសដល់កសិករដែលមានមុខរបរចិញ្ចឹមត្រីស្រាប់ និងកសិករថ្មីដែលមិនទាន់មានបទពិសោធន៍ចិញ្ចឹមត្រីនៅឡើយ។ លទ្ធផលដែលទទួលបានពីគម្រោងផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្មទ្រង់ទ្រាយតូចនៅប្រទេសភូមា (ជាគម្រោងផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្មទ្រង់ទ្រាយតូច ដើម្បីកែលំអជីវភាពរស់នៅរបស់សហគមន៍ជនបទពីឆ្នាំ ២០០៩ ដល់ឆ្នាំ២០១៣ ) មានភាពប្រហាក់ប្រហែលគ្នានឹងគម្រោងអភិវឌ្ឍវារីវប្បកម្មប្រភេទត្រីទីឡាព្យ៉ានៅប្រទេសម៉ាដាកាស្កា ឆ្នាំ២០០២ ដល់ឆ្នាំ ២០០៤ ។*

## ១. ការធ្វើឱ្យប្រសើរឡើងនូវបច្ចេកទេសផលិតកូនត្រី

ក. ការជ្រើសរើសទីកន្លែង និងការគ្រប់គ្រងទឹក

ខ. បច្ចេកទេសបង្កាត់ និងការប្រើប្រាស់អ័រម៉ូនដែលជម្រុញឱ្យទម្លាក់ពង

គ. ការគ្រប់គ្រងឱ្យបានត្រឹមត្រូវនូវមធ្យោបាយបង្កាត់ ភ្ញាស់ (ដូចជា ស្រះឬអាងត្រីមេពូជ អាងបង្កាត់ ភ្ញាស់ អាងថែបំប៉នកូនត្រី )

ឃ. ការគ្រប់គ្រងត្រីមេពូជ

ង. ការគ្រប់គ្រងបច្ចេកទេសបង្កាត់ ភ្ញាស់ និងថែបំប៉ន

ច. ការគ្រប់គ្រងបច្ចេកទេសរៀបចំ និងផ្តល់ចំណីត្រី

ឆ. ការប្រមូលផលកូនត្រី ការវេចខ្ចប់កូនត្រី និងការដឹកជញ្ជូនកូនត្រី ។

## ២. *ការធ្វើឱ្យប្រសើរឡើងនូវបច្ចេកទេសចិញ្ចឹមត្រី*

ក. ប្រព័ន្ធចិញ្ចឹមត្រី រួមមានការអនុវត្តបច្ចេកទេសចិញ្ចឹមចម្រុះជាលក្ខណៈវិបុលវប្បកម្មនៅទីកន្លែងណាដែលមានភាពសមស្រប

ខ. ប្រព័ន្ធកសិដ្ឋានចិញ្ចឹមចម្រុះដែលមានភាពសមស្របសម្រាប់វារីវប្បកម្មទ្រង់ទ្រាយតូច (ដូចជា ការចិញ្ចឹមត្រីក្នុងស្រែ ចិញ្ចឹមត្រីជាមួយសត្វ)

គ. ប្រភពនិងការផ្គត់ផ្គង់កូនត្រីពូជដែលមានគុណភាពល្អសម្រាប់ដាក់ចិញ្ចឹម

ឃ. ការជ្រើសរើសទីកន្លែង ការរៀបចំប្លង់ស្រះ និងទំហំស្រះ

ង. ការរៀបចំស្រះ រៀបចំជី និងការគ្រប់គ្រងគុណភាពទឹក

ច. ការគ្រប់គ្រងបច្ចេកទេស ការរៀបចំ និងការផ្តល់ចំណីត្រី

ឆ. ការគ្រប់គ្រងវារីវប្បកម្មល្អ ដើម្បីការពារ និងត្រួតពិនិត្យជំងឺ (ប្រសិនបើចាំបាច់) ។

## ៣. *ផលិតកម្មត្រីដើម្បីទីផ្សារ និងតម្លៃនៃសង្វាក់ផលិតកម្ម*

ក. ការរួមបញ្ចូលគ្នារវាងផលិតកម្មវារីវប្បកម្ម និងលទ្ធភាពរកទីផ្សារ

ខ. ប្រើប្រាស់កិច្ចសន្យាចិញ្ចឹមជាមួយនឹងតម្លៃព្រមព្រៀងដំបូងសម្រាប់ដាក់ចិញ្ចឹមនិងប្រមូលផល ដែលជាវិធីអាចជួយកាត់បន្ថយនូវការប្រកួតប្រជែងទីផ្សារ និងបង្កើតប្រាក់ចំណូលជាច្រើនដែលអាចប៉ាន់ស្មានបានសម្រាប់កសិករ។

## ៤. *ការធ្វើឱ្យប្រសើរឡើងនូវបច្ចេកទេស គំនិតច្នៃប្រឌិតថ្មីៗ និងការផ្សព្វផ្សាយ*

ក. ការវាយតម្លៃលើរបៀបគ្រប់គ្រងផ្សេងៗគ្នា

ខ. ជម្រុញការផ្សព្វផ្សាយវារីវប្បកម្មសម្រាប់ប្រភេទត្រីក្នុងស្រុក រួមមានការចិញ្ចឹមសាកល្បងនូវប្រភេទត្រីដែលសមស្របសម្រាប់វារីវប្បកម្ម

គ. ពង្រឹងបណ្តាញផ្សព្វផ្សាយពីកសិករទៅកសិករ និងការសម្របតាមរបៀបគ្រប់គ្រងជាក្រុម កសិដ្ឋានសម្រាប់កសិករទ្រង់ទ្រាយតូច

ឃ. ជម្រុញការផ្សព្វផ្សាយនូវការអនុវត្តតាមរបៀបគ្រប់គ្រងវារីវប្បកម្មល្អ សម្រាប់កសិដ្ឋានដែលមានភាពទទួលខុសត្រូវ

ង. ស្វែងរកលទ្ធភាពនៃការគាំទ្រពីរដ្ឋាភិបាល សម្រាប់ការអនុវត្តកម្មវិធីផ្សព្វផ្សាយបន្ត និងការយកទៅអនុវត្តនៅតំបន់ផ្សេងទៀត (ដូចជា ការចិញ្ចឹមត្រីទឹកភ្លាវក្នុងស្រះ ) ។

# ៧. ការត្រួតពិនិត្យ និងវាយតម្លៃ

មានបញ្ហាគន្លឹះសំខាន់ពីរក្នុងការផ្សព្វផ្សាយវារីវប្បកម្ម ជាពិសេសចំពោះកសិករទ្រង់ទ្រាយតូចគឺការផ្តល់នូវជំបូន្មានមាន និងការត្រួតពិនិត្យ។ ការផ្តល់នូវជំបូន្មាន អាចធ្វើទៅបានតាមយៈវគ្គបណ្តុះបណ្តាល ការផ្តល់នូវប្រឹក្សាបច្ចេកទេស និងនៅពេលដែលក្រុមកសិករមានឱកាសទំនាក់ទំនងជាមួយគ្នាផ្ទាល់ដូចដែលបានរៀបរាប់ខាងលើ។ ចំពោះការត្រួតពិនិត្យនិងការវាយតម្លៃទៅលើសកម្មភាពផ្សព្វផ្សាយគួរអនុវត្តដោយមន្ត្រីផ្សព្វផ្សាយរបស់រដ្ឋាភិបាល និងក្រុមកសិករផលិតកូនត្រី ហើយលើកទឹកចិត្តឱ្យកសិករផលិតកូនត្រីនិងកសិករចិញ្ចឹមត្រី រក្សាទុកនូវកំណត់ត្រាអំពីព័ត៌មានសំខាន់ៗដូចខាងក្រោម ដោយបំបែកដោយឡែកនូវព័ត៌មានអំពីយ៉េនឌ័រ បើចាំបាច់៖

- ចំនួនកសិករដែលបានទទួលការបណ្តុះបណ្តាលបច្ចេកទេស
- ចំនួនកសិករដែលបានទទួលការបណ្តុះបណ្តាលបច្ចេកទេសហើយយកទៅអនុវត្តបានជោគជ័យ
- គុណភាពកូនត្រីពូជ និងចំណី
- ភាពជោគជ័យនៃការអនុវត្តវារីវប្បកម្មពីមួយពេលទៅមួយពេល
- វិធានការដោះស្រាយបញ្ហាជាបន្ទាន់ក្នុងកំឡុងពេលកំពុងអនុវត្តវារីវប្បកម្ម
- ការប្រែប្រួលផលិតភាពត្រីមេពូជ កូនត្រីពូជ ចំណី និងប្រាក់ចំណូលរបស់កសិករ។



**រូបភាពទី ៧៖** ការត្រួតពិនិត្យនិងវាយតម្លៃសកម្មភាពកសិករចិញ្ចឹមត្រីនិងកសិករផលិតកូនត្រីត្រូវបានធ្វើឡើងដោយការសំភាសន៍ជាក្រុម (ពីលើទៅឆ្វេង) ឬសំភាសន៍កសិករម្នាក់ៗ (រូបភាពទៅខាងស្តាំ ) និងសកម្មភាពចុះពិនិត្យជាប្រចាំនូវ ការអនុវត្តវារីវប្បកម្មរបស់កសិករ (រូបភាពនៅខាងក្រោម ) ។

ការត្រួតពិនិត្យ និងការវាយតម្លៃអាចអនុវត្តបានតាមរយៈការចុះពិនិត្យដល់កសិដ្ឋានផលិតកូនត្រី ឬដល់កសិកដ្ឋានចិញ្ចឹមត្រី ដោយធ្វើការសំភាសន៍ (ជាផ្លូវការ និងក្រៅផ្លូវការ) ជាមួយកសិករម្នាក់ៗ និងកសិករជាក្រុម ឬកសិករនៅក្នុងបណ្តាញកសិករផលិតកូនត្រី (រូបភាពទី ៧)។ ឧទាហរណ៍នៅប្រទេសកម្ពុជា ការវាយតម្លៃលើការអនុវត្តសកម្មភាពផលិតកម្មកូនត្រី និងចិញ្ចឹមត្រីរបស់កសិករផលិតកូនត្រី និងកសិករចិញ្ចឹមត្រី ពាក់ព័ន្ធនឹងបញ្ហាសំខាន់ៗអំពីការផ្សព្វផ្សាយវារីវប្បកម្មទ្រង់ទ្រាយតូច គឺអាចអនុវត្តបានតាមរយៈការចុះធ្វើសំភាសន៍ និងពេលរៀបចំសិក្ខាសាលាកសិករ (រដ្ឋបាលជលផលនិងអង្គការយ៉ៃកា ឆ្នាំ២០១៤)។ ការជួបសំភាសន៍ពាក់កណ្តាលផ្លូវការគឺអាចប្រើបានសម្រាប់ប្រមូលព័ត៌មានសំខាន់ៗនៅពេលជួបជជែកលេងជាមួយកសិករ។ ការធ្វើបទសំភាសន៍បែបនេះមិនចាំបាច់តម្រូវឱ្យមានបញ្ជីសំណួរពេញលេញនោះទេ

គឺមន្ត្រីផ្សព្វផ្សាយអាចសួរបន្ថែម ឬកែប្រែសំណួរណាមួយ ដោយអាស្រ័យទៅនឹងដំណើរនៃការធ្វើការសំភាសន៍ និងការឆ្លើយតបរបស់កសិករ។ បន្ទាប់មក មន្ត្រីផ្សព្វផ្សាយត្រូវផ្តោតការយកចិត្តទុកដាក់លើការឆ្លើយតបរបស់កសិករ ដើម្បីកំណត់រកបញ្ហាជាក់លាក់ដែលទាក់ទងនឹងសកម្មភាពវារីវប្បកម្ម និងការចិញ្ចឹមជីវិតរបស់ពួកគាត់ ។

ការវិភាគបញ្ហា ឬការលំបាកដែលកសិករបានលើកឡើង គួរតែអនុវត្តនៅពេលធ្វើការសំភាសន៍ជាមួយនឹងកសិករចប់សព្វគ្រប់ (ការចុះត្រួតពិនិត្យ និងវាយតម្លៃ )។ វិធានការសមស្រប គួរតែត្រូវស្នើឡើង ដើម្បីអនុវត្ត និងដោះស្រាយបញ្ហា ឬការលំបាកដែលបានរកឃើញ។ វិធានការនេះនឹងមានគោលបំណងសំដៅធ្វើឱ្យប្រសើរឡើងនូវផលិតកម្មកូនត្រីពូជ និងការចិញ្ចឹមត្រីរបស់កសិករទ្រង់ទ្រាយតូច។ វិធីសាស្ត្របញ្ចូលបញ្ហាយ៉ែនឌ័រទៅក្នុងការងារកសិករ និងការវិភាគរកបញ្ហាការលំបាក គួរតែអនុវត្តព្រមគ្នា ដើម្បីដោះស្រាយបាននូវរាល់គ្រប់បញ្ហានិងការលំបាកដែលបានកើតឡើង។

# ៨. ឯកសារយោង

Chikami, S. (2013). JICA and small-scale aquaculture development. In: JICA, NACA and DOF, Proceedings of the International Symposium on Small-scale Freshwater Aquaculture Extension. Japan International Cooperation Agency, Tokyo, Japan, Network of Aquaculture Centres in Asia-Pacific, Bangkok, Thailand, and Royal Thai Department of Fisheries, Bangkok, Thailand. p. 1-2.

FiA and JICA (2014). Guidelines on Aquaculture Extension – Freshwater Aquaculture Improvement and Extension Project in Cambodia, Phase 2 (FAIEX-2). Fisheries Administration in Cambodia, Phnom Penh, Cambodia and Japan International Cooperation Agency, Tokyo, Japan. 25 pp.

JICA, NACA and DOF (2013). Proceedings of the International Symposium on Small-scale Freshwater Aquaculture Extension. Japan International Cooperation Agency, Tokyo, Japan, Network of Aquaculture Centres in Asia-Pacific, Bangkok, Thailand, and Royal Thai Department of Fisheries, Bangkok, Thailand. 89 pp.

Yamao, M. (2013). Further development of inland aquaculture: towards poverty alleviation and food security in rural areas. In: JICA, NACA and DOF, Proceedings of the International Symposium on Small-scale Freshwater Aquaculture Extension. Japan International Cooperation Agency, Tokyo, Japan, Network of Aquaculture Centres in Asia-Pacific, Bangkok, Thailand, and Royal Thai Department of Fisheries, Bangkok, Thailand. p. 3-4.

Viseth, H., C. Da and Y. Niwa (2013). Small-scale aquaculture extension implemented by the freshwater aquaculture improvement and extension project phase 2 (FAIEX-2) in Cambodia. In: JICA, NACA and DOF, Proceedings of the International Symposium on Small-scale Freshwater Aquaculture Extension. Japan International Cooperation Agency, Tokyo, Japan, Network of Aquaculture Centres in Asia-Pacific, Bangkok, Thailand, and Royal Thai Department of Fisheries, Bangkok, Thailand. p. 20-22

Japan International Cooperation Agency

Network of Aquaculture Centres in Asia-Pacific

